# សុន្ទរកថារបស់លោក យូណាមីណិ ម៉ូរីយ៉ាស៊ូ
# លេខាទី២ នៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធការកែលម្អអគារវះកាត់ និងពិធីប្រគល់បរិក្ខារវេជ្ជសាស្ត្រក្នុង
# មន្ទីរពេទ្យបង្អែកពារាំង ខេត្តព្រៃវែង
# ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០១៤

- **សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!**
- **សូមគោរព ឯកឧត្តម ស៊ា ហួង អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល**
- **សូមគោរព ឯកឧត្តម ឡុង ថាច អភិបាលរងនៃគណៈអភិបាលខេត្តព្រៃវែង**
- **សូមគោរព វេជ្ជបណ្ឌិត សេង បញ្ញារិទ្ធ ប្រធានមន្ទីរសុខាភិបាលខេត្តព្រៃវែង**
- **សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានមកចូលរួមពិធីសម្ពោធ និងប្រគល់នៅមន្ទីរពេទ្យបង្អែកពារាំងនេះ ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម.........អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល។ ជាបឋមខ្ញុំសូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅចំពោះឯកឧត្តមអនុរដ្ឋលេខាធិការ ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ដែលបានអញ្ជើញមកចូលរួមក្នុងពិធីនេះ។

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងនៅក្នុងការកសាងឡើងវិញនិងការអភិវឌ្ឍប្រទេសរបស់ខ្លួន ហើយក៏បានធ្វើអោយសម្រេចនូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់បំផុតរបស់ខ្លួន ស្មើនឹងបណ្តាប្រទេសកំពុងរីកចំរើនក្នុងតំបន់អាស៊ាន។ នៅក្នុងវិស័យសុខាភិបាល ទាំងបរិមាណនិងគុណភាពមានភាពប្រសើរឡើងយ៉ាងខ្លាំងផងដែរ តាមរយៈកិច្ចសហប្រតិបត្តិការរវាងក្រសួងសុខាភិបាល និងសហគមន៍អន្តរជាតិ។

រដ្ឋាភិបាលជប៉ុនបាននឹងកំពុងបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីធ្វើអោយប្រសើរឡើងនូវការថែទាំសុខភាព តាមរយៈការអភិវឌ្ឍន៍ធនធានមនុស្ស និងការកែលម្អអគារថែទាំវេជ្ជសាស្ត្រ។

ការកែលម្អអគារវះកាត់ និងបរិក្ខាវេជ្ជសាស្ត្រផ្តល់ជូន តាមរយៈជំនួយឥតសំណងទ្រង់ទ្រាយតូចរបស់ជប៉ុន នឹងអនុញ្ញាតអោយអ្នកជម្ងឺកាន់តែច្រើនឡើងទទួលបានការព្យាបាលប្រកបដោយសុវត្ថិភាព និងក្នុងបរិស្ថានប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ហើយសង្ឃឹមថាគម្រោងនេះ នឹងរួមចំណែកជួយកែលម្អធ្វើអោយប្រសើរឡើងស្ថានភាពសុខភាពនៅក្នុងតំបន់។

សមាគមកំចាត់រោគរបេងជប៉ុន បានរួមចំណែកដល់ការកាត់បន្ថយអត្រានៃការឆ្លងមេរោគរបេងនៅមន្ទីរពេទ្យនេះ។ រដ្ឋាភិបាលជប៉ុន ក៏គាំទ្រមូលនិធិដល់សមាគមនេះនៅក្នុងសកម្មភាពប្រឆាំងនឹងជំងឺរបេងនេះផងដែរ។

ខ្ញុំដឹងថា អង្គការបេះដូងជប៉ុន ជាអង្គការក្រៅរដ្ឋាភិបាលជប៉ុនមួយដែលបានជួយដល់ប្រតិបត្តិការវះកាត់នៅមន្ទីរពេទ្យនេះអស់រយៈពេលប្រាំឆ្នាំកន្លងមក ហើយដោយមានអគារវះកាត់ថ្មីនេះផងនេះ យើងរំពឹងថាសកម្មភាពរបស់ពួកគេនឹងទទួលបានប្រសិទ្ធភាពខ្ពស់។

ជាចុងក្រោយខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះ នឹងជួយជំរុញបន្ថែមទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុននិងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!